ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ...១៩៤...សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកោះកុង**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។

**យោង** ៖ -របាយការណ៍ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ០៨ ក្រុមហ៊ុន ស្ថិតក្នុងខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តកោះកុង រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**I- ខេត្តព្រះវិហារ**

**១-ក្រុមហ៊ុន ខេមបូឌា ដោន ផ្លេនថេសិន អិលធីឌី** (Cambodia Dawn Plantation Ltd)

១-អនុញ្ញាតឱ្យក្រុមហ៊ុន "ខេមបូឌា ដោន ផ្លេនថេសិន អិលធីឌី" (Cambodia Dawn Plantation Ltd) ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តព្រះវិហារ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**២-ក្រុមហ៊ុន មេត្រីភាព កសិ-ឧស្សាហកម្ម**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "មេត្រីភាព កសិ-ឧស្សាហកម្ម" ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រស្រុកជាំក្សាន្ត និងស្រុកគូលេន ខេត្តព្រះវិហារ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យា ដោយទុករយៈពេល ០១ (មួយ) ឆ្នាំ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តព្រះវិហារ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថាន ត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៣-ក្រុមហ៊ុន សុវណ្ណភូមិ វិនិយោគ កសិ-ឧស្សាហកម្ម ៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "សុវណ្ណភូមិ វិនិយោគ កសិ-ឧស្សាហកម្ម" ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រឃុំរម្មណីយ៍ ស្រុករវៀង ខេត្តព្រះវិហារ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យា ដោយទុករយៈពេល ០១ (មួយ) ឆ្នាំ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តព្រះវិហារ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថាន ត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**II- ខេត្តកំពង់ធំ**

**៤-ក្រុមហ៊ុន រាម ណា វិនិយោគ ខូអិលធីឌី ៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "រាម ណា វិនិយោគ ខូអិលធីឌី" ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តព្រះវិហារ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំកៅ/

ស្សិរួចចំនួន ២៧ (ម្ភៃប្រាំពីរ) ហិកតា ដើម្បីចុះកិច្ចសន្យា និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៥-ក្រុមហ៊ុន សល សុភា ពាណិជ្ជ គ្រុប (SAL SOPHEA PEANICH GROUP CO., LTD)៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "សល សុភា ពាណិជ្ជ គ្រុប" (SAL SOPHEA PEANICH GROUP CO., LTD) ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៦-ក្រុមហ៊ុន C.A.D.I CO., LTD៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "C.A.D.I CO., LTD" ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តព្រះវិហារ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាដោយទុករយៈពេល ០១ (មួយ) ឆ្នាំ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ធំ និងខេត្តព្រះវិហារ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## III- ខេត្តកោះកុង

**៧-ក្រុមហ៊ុន SINOMEXIM Investment Co., Ltd៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "SINOMEXIM Investment Co., Ltd" ក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រខេត្តកោះកុង បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញដោយទុករយៈពេល ០១ (មួយ) ឆ្នាំ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកោះកុង ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការ/

កំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៩-ក្រុមហ៊ុន JW Cambodia Eco Holidays ៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន "JW Cambodia Eco Holidays" ក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រខេត្តកោះកុង បន្តនីតិវិធីជាធរមានដើម្បីចុះកិច្ចសន្យា ដោយទុករយៈពេល **០១ (មួយ) ឆ្នាំ** និងកែសម្រួលរយៈពេលវិនិយោគពី **៨០ (ប៉ែតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកោះកុង ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថាន ត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**[illegible] សំរេច**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរ៉ែ និងថាមពល
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ